**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:៦៨
ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨

**<u>សាលដីកា</u>**
លេខ:៣៤
ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ................ ជាចៅក្រមជាចៅក្រមរបាយការណ៍
៥-លោក ............. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក ............

**<u>តំណាងមហាអយ្យការ</u>**

-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៧៦៩ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៨៦ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះសមភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ របរនាយកវិទ្យាល័យ១ឧសភា ទីលំនៅសព្វថ្ងៃភូមិព្រៃឈើទាលក្រោម ឃុំអង្គតាសោម ស្រុក ត្រពាំកក់ ខេត្តតាកែវ ឪពុកឈ្មោះសៅ ម៉ឹង(ស) ម្តាយឈ្មោះអ៊ុក មុត (រ) ប្រពន្ធឈ្មោះសាំង សារឹម មានកូន៤នាក់ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះអនភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ របរធ្វើស្រែទីលំនៅភូមិខ្លាគ្រហឹម ឃុំតាកែម ស្រុកត្រាំកក់ ខេត្តតាកែវ ។ ឪពុកឈ្មោះអ៊ុយ បិទ (ស) ម្តាយឈ្មោះម៉ុត អ៊ឹម (ស) ប្រពន្ធឈ្មោះថោង សំណាង មានកូន១១នាក់ ។

**<u>កម្មវត្ថុប្តឹង</u>** ទាមទារសាលារៀនរក្សាជាសម្បត្តិសាធារណៈនិងសុំឱ្យចុងចម្លើយរុះរើផ្ទះចេញពីដីទំនាស់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២១ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ របស់ឈ្មោះសមប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៧៦៩ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍លើសាលដីកាទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៦៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៤-០១-៩៦ របស់ឈ្មោះសមប្តឹងពីឈ្មោះអនទាមទារដីសាលារៀនមករក្សាទុកជាសម្បត្តិសាធារណៈ ដោយហេតុថា១៩៨១ ឈ្មោះអ៊ុយ នាង បានសុំអនុញ្ញាតពីលោកអ៊ីវ សារិតនាយកសាលាដើម្បីស្នាក់នៅជាបណ្តោះអាសន្នសិនទំរាំរកដំរកស្នាក់នៅបាន។ ពេល លោក អ៊ីវ សារិត និងរដ្ឋអំណាចបានរកផ្ទះនិងដីឱ្យគាត់នៅ ប៉ុន្តែឈ្មោះអននៅតែមិនព្រមចេញពីដីនេះរហូតដល់សព្វថ្ងៃ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២០១ (ខ) ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៧ របស់តុលាការសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី៤-០១-៩៦ របស់លោកសម(ដើមចោទ) ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២- បដិសេធបណ្តឹងតប ចុះថ្ងៃទី៥-២-៩៦ របស់លោកអន(ចុងចម្លើយ) ចោលជាអសារបង់ ។

៣-ដីដែលមានទំហំ៧២៥៤២ ម៉ែត្រការ៉េមានព្រំប្រទល់ខាងជើងទល់ផ្លូវចូលវត្ត ខាងត្បូងទល់ទំនប់ទឹក ខាងកើតទល់ដីឈ្មោះគង់ ហង់-ទូច រឿន -ញ៉ែម វ៉ាន -ទូច ដឹន -អ៊ុយ ម៉ុច -អ៊ុយ សឿន -ផង អ៊ុន- អ៊ុយ សេង និងឈ្មោះណុប សុផល និងខាលិចទល់ដីឈ្មោះកែវ អាន ស្រីឆែម -ទូច រឿន ឡុង សារុន និងឈ្មោះអៀង ច្រិប ។ ស្ថិតនៅភូមិខ្លាគ្រហឹម ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ត្រូវរក្សាទុកជាដីរបស់សាលារៀនវិទ្យាល័យ១ឧសភា ខ្លាគ្រហឹម ស្រុកត្រាំកក់ ខេត្តតាកែវ ។

៤. បង្គាប់ឱ្យចុងចម្លើយឈ្មោះអន(ចុងចម្លើយរុះរើលំនៅដ្ឋានចេញពីដីទំនាស់នេះក្នុងកំណត់រយៈពេលមួយខែ គិតចាប់តាំងពីថ្ងៃទីផុតកំណត់ប្តឹងឧទ្ធរណ៍ ។

៥- បង្គាប់ឱ្យឈ្មោះអនចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹង១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់២០០រៀល ចំណាយលើអ្នកប្រគល់ដីកាកោះ៥.០០០រៀល សរុប ៧.០០០រៀល ប្រាក់នេះត្រូវបានដកពីប្រាក់៧.០០០រៀល ដែលដើមចោទ បានបង់ទុករួច ។

កាលបើផុតកំណត់ឧទ្ធរណ៍បង្គាប់ឱ្យចុងចម្លើយឈ្មោះអនសងប្រាក់៧.០០០រៀល នេះឱ្យ ទៅដើមចោទវិញ ។

៦- បង្គាប់ឱ្យចុងចម្លើយឈ្មោះអនបង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីទំនាស់គឺ $\frac{\text{៤០៥០០០០០x១}}{\text{១០០}}$ =៤០៥.០០០រប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ៨០ភាគរយគឺ $\frac{\text{៤០៥០០០x៨០}}{\text{១០០}}$ = ៨២៤.៤០០រៀល និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយគឺ$\frac{\text{៤០៥០០០x២០}}{\text{១០០}}$= ៨១.០០០រៀល

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូក្តីបើកផ្ទះឧទ្ធរណ៍កំណត់៦០ថ្ងៃគិតចាប់តាំងពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៧ របស់ឈ្មោះអនមិនសុខចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ០១(ខ) ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៧ របស់តុលាការខេត្តតាកែវ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៦៩ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៧ របស់សលាឧទ្ធរណ៍នៃសម្រេចដូចតទៅ ៖

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០-១-៩៧ របស់ឈ្មោះអនទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២- បដិសេធសាលក្រមលេខ១(ខ) ចុះថ្ងៃទី៦-១-៩៧ របស់តុលាការខេត្តតាកែវចោលជាអសារបង់ ។

៣-ប្រគល់ ផ្ទះទំនាស់ដែលស្ថិតនៅលើដីទំនាស់ABEFទទឹង[AB][FE]=35m បណ្តោយ[AB]= [BE] ទល់នឹងចំការស្វាយចន្ទីដែលស្ថិតនក្នុងប្រវែង៤ម៉ែត្រ ចាប់ពីផ្ទះទំនាស់នាស់និងទីចាត់ការឱ្យទៅអនកាន់កាប់ជាកម្មសិទ្ធិចាប់ពីសាលដីកានេះចូលជាស្ថាពរ ។

៤- ដីនិងផ្ទេរ(ទីចាត់ការ)ដែលនៅសល់ក្រៅពីនេះប្រគល់ឱ្យសាលារៀន(មើលផែនទីបង្ហាញទីតាំងដីទំនាស់ចុះថ្ងៃទី១២.២.៩៦ របស់ការិយាល័យភូមិបាលស្រុកត្រាំកក់ និងចំណុចបង្កើតឡើងដោយសាលាឧទ្ធរណ៍នៅលើគំនូសប្លង់នោះ) ។

៥- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់៤៥០៛ ចំណាយលើដីកាកោះ៥.០០០៛ អាជ្ញាធរតុលាការ ៥០០០៛ ។

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងសាទុក្ខលេខ២១ ចុះថ្ងៃទី២២-០១-៩៨ របស់លោកសមស្ថិតក្នុងកំណត់

បានឃើញសារណាការពាររបស់ឈ្មោះសមចុះថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៩៨ ។

បានឃើញសារណាធ្វើយតបរបស់ឈ្មោះអនចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៨ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈសាលដីការដ្ឋប្បវេណីលេខ៧៦៩ ចុះថ្ងៃទី២៣.១២.៩៧ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះសមជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយថា៖ ដីជារបស់រដ្ឋមិនត្រូវមានមនុស្សណាមកនៅទេ ក្នុងភូមិរដ្ឋអំណាចភូមិរកដីឱ្យហើយ សាលាឧទ្ទរណ៍ សម្រេចឱ្យដីទៅគាត់មិនមែនទេដីប្រធានភូមិឱ្យមួយនាក់១០១Aដីនេះគាត់កំពុងកាន់កាប់ ហើយឱ្យផ្ទះទៀត ផងតាំងឆ្នាំ៨២ ហើយផ្ទះនេះចៅហ្វាយស្រុកយកបាត់ហើយដីប្តូរកន្លែង១កន្លែងជារបស់គាត់ចាស់ គាត់មិនយកដីទាំងនេះ គេយកអស់ហើយ ។ បើគាត់ទៅនៅកន្លែងឯណារដ្ឋអំណាចរកឱ្យ ។ ខ្ញុំជានាយក ពីឆ្នាំ៩២ មកទេ សាលាខ្លាគ្រហឹមនេះបង្កើតតាំងពីឆ្នាំ៨១មក ផ្ទះដែលថាឱ្យគាត់ គាត់យកមិនទាន់គេនោះតាមពិតគាត់មិនយក ។ សាលានោះគ្មានរបងអ្វីត្រឹមត្រូវទេ តែមានភូមិបាល កំណត់ត្រឹមត្រូវ ។ ខ្លាគ្រហឹមមានឈ្មោះជាសាលា៧៩ រដ្ឋអំណាចប្រគល់ឱ្យឆ្នាំ៨០ឆ្នាំ៨០គាត់ធ្វើជាមេឃុំ ។

បានស្តាប់ចម្លើយរបស់ឈ្មោះអនជាចុងចម្លើយបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា៖ ខ្ញុំចាំបានខ្លះដីប្តូរកន្លែងសមថាខ្ញុំមិនដែលស្គាល់ទេ គាត់មិនដែលជាន់ដីខ្ញុំទេ សូម្បីព្រំប្រទល់និងទំហំគាត់មិនដឹងផង និងគាត់មិនដែលទាក់ទងគ្នានិយាយរឿងដីធ្លីនេះទេ ដូចជាផ្ទះជាដើមគេមិនឱ្យទីទេ ឲ្យម្បីដីប្រធានភូមិមិនឱ្យផង ក្រោយមកដោយមានអន្តរាគមន៍ពីចៅហ្វាយស្រុកផង គេឱ្យផ្ទះនៅកន្លែងដើមវិញ ឯផ្ទះនោះគេថាឱ្យនោះសុទ្ធតែគេនៅអស់ទៅខ្ញុំតែផ្ទះនោះគេនៅរួចទៅហើយ ខ្ញុំហើយតាំងពីពេលនោះមក ។ ឆ្នាំ៧៩និង៨០-៨១ នណានៅត្រង់ណាក៏បានដែរ គេនៅរហូតដល់សព្វថ្ងៃនោះក្លាយជាកម្មសិទ្ធិរបស់គេរួចទៅហើយ តែខ្ញុំកម្មអ្វី បែរជាចង់ឱ្យខ្ញុំចេញពីដីនេះទៅវិញ តើឱ្យខ្ញុំចេញទៅនៅឯណា ។ សេចក្តីសន្និដ្ឋានរបស់មេធាវីចុងបណ្តឹងសាទុក្ខ : សាលារៀននេះមិនមែនជាសាលារៀនសោះ ព្រោះជាអាគារបាក់បែកមែនគាត់អនរស់នៅតាំងពីឆ្នាំ៨១ មកឆ្នាំ៩១ បែរជាមកព័ទ្ធយកដីទាំងដីស្រែគាត់ធ្វើតាំងពីឆ្នាំ៧៩ មកផង តាមអនុក្រឹត្យលេខ២៥ អនក្រ និងច្បាប់ភូមិបាល សូមឱ្យរដ្ឋធ្វើជាគោលនយោបាយឱ្យគាត់បើសិនណាឲ្យគាត់ចេញសូមទុកដីស្រែឲ្យគាត់ ។

អន: សូមឯកឧត្តមមេត្តា ចែករំលែកដីឱ្យខ្ញុំបាននៅផងខ្ញុំមិនទាស់ទេ បើយកដីនេះធ្វើសាលាធ្វើនោះ តែបើយកទាស់ កន្លងមកគេយកដីស្រែរបស់សាលាទៅដាំស្វាយចន្ទី សំរាប់ជាប្រយោជន៍របស់ខ្លួនទៅវិញ ដីស្រែខ្ញុំបានធ្វើកន្លងមកខ្ញុំសូមធ្វើដដែលវិញឆ្នាំ៨១ពេលខ្ញុំចូលនៅដី គ្មានសាលាទេ ជាកន្លែងកប់ខ្មោចទៀតផង គ្មានសិស្ស គ្មានគ្រូទេ បើសមថាឆ្នាំ៨១-៨២-៨៣-៨៤ ជាកន្លែងនោះមានសាលារកគ្រូមកបង្ហាញទៅ នៅឆ្នាំ៨៤ ទើបរំលែកសិស្សពីសាលា១ឧសភាមកកាន់កន្លែងនេះ ខ្ញុំនៅសព្វថ្ងៃជាអាគារចាស់របស់ប៉ុលពតមិនមែនសាលាទេ ខ្ញុំនៅសព្វថ្ងៃក៏ដើម្បីរក្សាការពារអាគារដែរ ។

ខ្ញុំបដិសេធពាក្យរបស់សមថាគ្រូគេចេញអស់ហើយ នៅតែខ្ញុំតាមពិតគ្រូៗមកនៅនោះគេមិនមកនៅកន្លែងខ្ញុំ នៅនេះទេ គេនៅសាលា១ឧសភា ឯណោះ ឃ្លាតពីគ្នា៦០០ ទៅ៧០០ម៉ែត្រ ។

ខ្ញុំសន្យាថា បើយកដីនេះធ្វើសាលាសូមធ្វើចុះ តែខ្ញុំសូមចំណែកដីផង លើដីនោះខ្ញុំដាំដូង ខ្នុរ ចេក ហើយឲ្យខ្ញុំចេញទៅណា?

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ២១ ចុះថ្ងៃទី២២-០១-៩៨ របស់លោកសមស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថាៈមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាៈ ចុងចម្លើយពិតជាបានខ្ចីដីសាលារៀនស្នាក់នៅបណ្តោះអាសន្នពិតប្រាកដមែន ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់ដីទំនាស់ឱ្យទៅចុងចម្លើយជាការភ័ន្តច្រឡំ ពីព្រោះថា ទីតាំងផ្ទះ និងដីទំនាស់របស់ចុងចម្លើយស្ថិតនៅក្នុងបរិវេណសាលារៀនដែលជាដីសាធារណៈ ហើយដែលតាមមាត្រ៥ នៃច្បាប់ភូមិបាល និងមាត្រា៦នៃអនុក្រឹត្យលេខ២៥ អនក្រ ចុងចម្លើយពុំអាចមាន សិទ្ធិជាកម្មសិទ្ធិលើដី និងអាគារនេះបានឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧៦៩ ចុះថ្ងៃទី២៣-១២- ៩៧ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## ឧទ្ធ័យសេចក្ត ចំពោះមុខគក្ត

១- ទទួលបណ្តឹងសាទុក្ខលេខ២១ ចុះថ្ងៃទី២២-០១-៩៨ របស់លោកសមទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៧៦៩ ចុះថ្ងៃទី២៣-១២- ៩៧ របស់សាលាឧទ្ធរណ៍

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៦៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកសមបានបង់ទុកនៅតុលាការកំពូលចំនួន១៩០០០៛ គឺ - ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០ សម្រាប់ជា រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ។

ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

ហើយតម្រូវឱ្យលោកអនសងប្រាក់ចំនួន១៩.០០០៛ នេះទៅលោកសមវិញ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ។